*[សូមផ្ទៀងផ្ទាត់ តាមការអាន]*

# សុន្ទរកថា
# អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី,
# រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
# ថ្លែងក្នុង
# ពិធីបើកកម្មវិធីផ្លាស់ប្តូរចំណេះដឹង ក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក

(Asia-Pacific Knowledge Exchange - APKE)

រាជធានីភ្នំពេញ, ថ្ងៃចន្ទ ៨ រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

ត្រូវនឹងថ្ងៃទី ១ ខែ មេសា គ.ស. ២០២៤ វេលាម៉ោង ៩:០០ ព្រឹក,

នៅសណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា

- ឯកឧត្តម Lautimuia Afoa Uelese Vaai រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុសាម័រ;
- លោកស្រី Tariye Gbadegesin នាយិកាប្រតិបត្តិនៃមូលនិធិវិនិយោគអាកាសធាតុ (Climate Investment Fund - CIF);
- លោក Warren Evans ទីប្រឹក្សាជាន់ខ្ពស់ពិសេស ទទួលបន្ទុកលើបញ្ហាប្រែប្រួលអាកាសធាតុ នៃធនាគារអភិវឌ្ឍន៍អាស៊ី (ADB);
- លោកស្រី Jyotsana Varma នាយិកាស្ថានតំណាងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ប្រចាំកម្ពុជា;
- ឯកឧត្តម, លោកជំទាវ, ជាតំណាងក្រសួង-ស្ថាប័ននៃរាជរដ្ឋាភិបាលកម្ពុជា;
- ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី !

ថ្ងៃនេះ, ខ្ញុំពិតជាមានសេចក្តីសោមនស្សយ៉ាងក្រៃលែង ដោយបានធ្វើជាតំណាងរាជរដ្ឋាភិបាលកម្ពុជា និង ជាអធិបតី ក្នុងពិធីបើក **«កម្មវិធីផ្លាស់ប្តូរចំណេះដឹង ក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក** (Asia-Pacific Knowledge Exchange)» ។ ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, ជាតំណាងប្រទេស

ទាំង ១៤ នៅក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក, ក៏ដូចជា ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី, ជាតំណាងក្រសួង-ស្ថាប័ន, ដៃគូអភិវឌ្ឍន៍, គ្រឹះស្ថានឧត្តមសិក្សា, ស្ថាប័នស្រាវជ្រាវ និង វិស័យឯកជននៅក្នុងព្រះរាជាណាចក្រកម្ពុជា, ព្រមទាំងតំណាងសហគមន៍ជនជាតិដើមភាគតិច និង ក្រុមសហគមន៍មូលដ្ឋានពីតាមប្រទេសនានា, ដែលបានឆ្លៀតពេលដ៏មានតម្លៃ អញ្ជើញចូលរួមក្នុងកម្មវិធីដ៏មានសារៈសំខាន់របស់យើង នាឱកាសនេះ ។

នេះ គឺជាថ្ងៃដ៏មហានក្ខត្តឫក្ស ដែលរាជរដ្ឋាភិបាលកម្ពុជា, រួមសហការជាមួយ **មូលនិធិវិនិយោគអាកាសធាតុ** និង **ធនាគារអភិវឌ្ឍន៍អាស៊ី**, បានរៀបចំនូវ **«កម្មវិធីផ្លាស់ប្តូរចំណេះដឹង ក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក»** ដោយបានប្រមូលផ្តុំសមាសភាព ជាថ្នាក់ដឹកនាំ, អ្នកតំណាង និង មន្ត្រីជំនាញនៃក្រសួង-ស្ថាប័នពាក់ព័ន្ធនានា, ពីតាមបណ្តាប្រទេសជាសមាជិកនៃ**មូលនិធិវិនិយោគអាកាសធាតុ**, ដើម្បីចែករំលែកចំណេះដឹង, បទពិសោធន៍, មេរៀន និង មតិយោបល់ សំដៅចូលរួមដោះស្រាយបញ្ហាប្រឈមនៃការប្រែប្រួលអាកាសធាតុ នៅតំបន់អាស៊ី-ប៉ាស៊ីហ្វិក ដែលបាន និង កំពុងក្លាយជាបញ្ហាស្មុគស្មាញមួយនាយុគសម័យថ្មីនេះ ដើម្បីឈានទៅសម្រេចបាន នូវភាពធន់នឹងការប្រែប្រួលអាកាសធាតុ ។

ឆ្លៀតក្នុងឱកាសដ៏វិសេសនេះ, ខ្ញុំសូមគូសរំលេចផងដែរថា ការប្រែប្រួលអាកាសធាតុ គឺជាបញ្ហារួមរបស់ពិភពលោកទាំងមូល ដែលទាមទារឱ្យយើងទាំងអស់គ្នា ចូលរួមចាត់វិធានការដោះស្រាយ ប្រកបដោយការទទួលខុសត្រូវ និង ការប្តេជ្ញាចិត្តខ្ពស់ ដើម្បីកាត់-បន្ថយភាពងាយរងគ្រោះ តាមរយៈការកសាងភាពធន់ និង ការបន្សាំខ្លួន ឱ្យបានកាន់តែប្រសើរ ។ ការប្រែប្រួលអាកាសធាតុ មិនត្រឹមតែបានបង្កឱ្យភពផែនដីឡើងកម្តៅប៉ុណ្ណោះទេ, ប៉ុន្តែថែមទាំង បានបង្កឱ្យមានគ្រោះមហន្តរាយធម្មជាតិ កាន់តែញឹកញាប់ និង មានសភាពកាន់តែធ្ងន់ធ្ងរទៅៗ ។ អាស៊ី, ដែលមានប្រជាជនប្រមាណ ៦០% នៃប្រជាជនសរុបលើពិភពលោក, ស្ថិតក្នុងចំណោមតំបន់ដែលងាយរងគ្រោះជាងគេ ដោយសារការប្រែប្រួលអាកាសធាតុ ។ ជាក់ស្តែង, កាលពីឆ្នាំ ២០២២, ក្នុងតំបន់អាស៊ី, គ្រោះធម្មជាតិបានបំផ្លិចបំផ្លាញលំនៅដ្ឋានរបស់ប្រជាជន ប្រមាណជាង ៥០ លាននាក់ និង បង្កឱ្យមានការខាតបង់សេដ្ឋកិច្ច រហូតដល់ប្រមាណ ៨០ ពាន់លានដុល្លារអាមេរិក ។ ករណីនេះ សបញ្ជាក់ច្បាស់ អំពីភាពធ្ងន់ធ្ងរ និង ភាពងាយរងគ្រោះ ដែលបង្កឡើងដោយការប្រែប្រួលអាកាសធាតុ ។ ជាងនេះទៀត, ការឡើងកម្តៅនៃភពផែនដី ក៏កំពុងតែ

ដាក់សម្ពាធកាន់តែធ្ងន់ លើការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និង ការការពារបរិស្ថានរបស់យើង ផងដែរ ។ បញ្ហាប្រឈមទាំងនេះ បាន និង កំពុងគម្រាមកំហែង ដល់កាលានុវត្តភាព ក្នុងការធានាបាន នូវពិភពលោកមួយដែលគួរឱ្យចង់រស់នៅ សម្រាប់យើងទាំងអស់គ្នា, ជាពិសេស សម្រាប់មនុស្សជំនាន់ក្រោយទៀត, នេះម្យ៉ាង; និង ម្យ៉ាងទៀត, គឺជាសារដាស់តឿនដល់ថ្នាក់ដឹកនាំ នៅទូទាំងសកលលោក អំពីភាពចាំបាច់ និង ភាពបន្ទាន់ ក្នុងការដោះស្រាយបញ្ហាប្រឈមទាំងនេះ ប្រកបដោយប្រសិទ្ធភាព និង ស័ក្តិសិទ្ធភាពខ្ពស់ ។

ក្នុងន័យនេះ, ខ្ញុំសូមសម្តែងនូវការគាំទ្រ និង ការសាទរ ចំពោះ «**មូលនិធិវិនិយោគអាកាសធាតុ** - Climate Investment Fund» ឬ ហៅកាត់ថា «CIF» ដែលបានគិតគូរម៉ត់ចត់លើបញ្ហានេះ ដោយបានផ្តួចផ្តើម និង សហការយ៉ាងជិតស្និទ្ធជាមួយរាជរដ្ឋាភិបាលកម្ពុជា និង ធនាគារអភិវឌ្ឍន៍អាស៊ី ក្នុងការរៀបចំ «**កម្មវិធីផ្លាស់ប្តូរចំណេះដឹង ក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក**» នេះឡើង នៅក្នុងព្រះរាជាណាចក្រកម្ពុជា, ពោលគឺ ការគិតគូររៀបចំនេះពិតជាសមស្រប, ទាន់ពេល និង ចំទិសដៅ ។ **មូលនិធិវិនិយោគអាកាសធាតុ** ក៏បាន និង កំពុងគាំទ្រ លើការពង្រឹងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ក្នុងទំហំហិរញ្ញប្បទានសរុបប្រមាណ ១១,៥ ពាន់លានដុល្លារអាម៉េរិក និង មានសក្តានុពល ក្នុងការទាក់ទាញធនធានបន្ថែម ប្រមាណ ៦៣ ពាន់លានដុល្លារអាម៉េរិក, ក្រោមទម្រង់ជាសហហិរញ្ញប្បទាន, ដើម្បីជំរុញការអភិវឌ្ឍ សំដៅឈានទៅរកភាពធន់នឹងការប្រែប្រួលអាកាសធាតុ នៅក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក ប្រកបដោយប្រសិទ្ធភាព ។

## ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី!

ក្នុងរយៈពេល ២៦ ឆ្នាំចុងក្រោយ, បន្ទាប់ពីការសម្រេចបាននូវសុខសន្តិភាពពេញលេញ, ឯកភាពជាតិ និង ឯកភាពទឹកដីទាំងស្រុង តាមរយៈ **នយោបាយឈ្នះ-ឈ្នះ** របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**, អតីតនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា, រាជរដ្ឋាភិបាលកម្ពុជា សម្រេចបាននូវសមិទ្ធផលធំៗ លើគ្រប់វិស័យ, ទាំងនយោបាយ, សង្គម, និង សេដ្ឋកិច្ច, ដែលនាំឱ្យកម្ពុជា មានការផ្លាស់ប្តូរមុខមាត់ថ្មី គួរជាទីមោទនៈបំផុត ។

ពេលនេះ, ដំណើរការកសាងជាតិរបស់កម្ពុជា បានឈានដល់ដំណាក់កាលថ្មីមួយ នៅក្នុងបរិការណ៍នៃពិភពលោក ដែលកាន់តែប្រែប្រួល, លំបាក និង មិនប្រាកដប្រជា ។

ស្របពេលដែលបង្គោលចរ ឆ្នាំ ២០៣០ នៃការប្រែក្លាយកម្ពុជា ទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ កាន់តែខិតជិតមកដល់, ពោលគឺ នៅសល់ប្រមាណ ៦ ឆ្នាំ ទៀតប៉ុណ្ណោះ, ទស្សនអនាគតនៃកំណើនរបស់កម្ពុជា ត្រូវបានបន្តហ៊ុមព័ទ្ធ ដោយហានិភ័យ និង ភាពមិនប្រាកដប្រជាខ្ពស់ ពីកត្តាធំៗខាងក្រៅ មានជាអាទិ៍៖ ភាពតានតឹងនៃភូមិសាស្ត្រនយោបាយ, កំណើនទាបនៃសេដ្ឋកិច្ចសកល ដែលបណ្ដាលមកពីសង្គ្រាមពាណិជ្ជកម្ម, ការបន្តរឹតបន្តឹងគោលនយោបាយរូបិយវត្ថុរបស់ប្រទេសអភិវឌ្ឍន៍ ក្នុងការឆ្លើយតបទៅនឹងសម្ពាធអតិផរណា, ការអូសបន្លាយនៃសង្គ្រាមរវាងរុស្ស៊ី និង អ៊ុយក្រែន, ការប្រយុទ្ធគ្នារវាងអ៊ីស្រាអែល និង ក្រុមហាម៉ាស ។ល។ លើសពីនេះទៀត, ការប្រែប្រួលអាកាសធាតុ, ដែលជាបញ្ហាប្រឈមរួមរបស់មនុស្សជាតិទាំងមូល, ក៏កំពុងតែបង្កផលប៉ះពាល់អវិជ្ជមានកាន់តែធ្ងន់ធ្ងរផងដែរ ។

យ៉ាងណាក៏ដោយ, កម្ពុជានៅតែមានសក្ដានុពល និង កាលានុវត្តភាពជាច្រើន, ទាំងខាងក្រៅ និង ក្នុងប្រទេស, សម្រាប់ពន្លឿនការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចរបស់ខ្លួន ក្នុងនោះរួមមាន ៖ ១).ការផ្លាស់ប្ដូរកាន់តែលឿននៃច្រវាក់ផលិតកម្ម ពីតំបន់ និង ប្រទេសផ្សេងៗមកកាន់អាស៊ាន, ដែលធ្វើឱ្យកម្ពុជាអាចទាញប្រយោជន៍មួយចំនួន ពីចលនការនេះ; ២).កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី, ទាំងក្នុងក្របខណ្ឌតំបន់ និង ទ្វេភាគី; ៣).ផលលាភសន្តិភាព តាមរយៈការបន្តរក្សាបាននូវសុខសន្តិភាព និង ស្ថិរភាពនយោបាយ; ៤).ការ-អភិវឌ្ឍ និង ការពង្រឹងបានល្អ នូវតួនាទី និង ស្ថិរភាព នៃវិស័យហិរញ្ញវត្ថុ; ៥).ការអភិវឌ្ឍ និង ការពង្រឹងសមត្ថភាព នៃឧស្សាហកម្មគាំទ្រក្នុងស្រុក នៅក្នុងការបង្កើនតម្លៃបន្ថែម និង ការលើកកម្ពស់ភាពប្រកួតប្រជែងនៃវិស័យឧស្សាហកម្ម; ៦).ការចាប់យកប្រយោជន៍ពីផលលាភប្រជាសាស្ត្រ, វិស័យឌីជីថល និង វិស័យថ្មីៗ ដែលមានសក្ដានុពល; និង ៧).ការជំរុញកិច្ចការកែទម្រង់ជារចនាសម្ព័ន្ធ និង ការរៀបចំយន្តការអនុវត្ត ឱ្យបានច្បាស់លាស់ និង ប្រកបដោយប្រសិទ្ធភាពខ្ពស់ ដែលនឹងចូលរួមចំណែកយ៉ាងសំខាន់ដល់ការជំរុញកំណើនសេដ្ឋកិច្ចក្នុងស្រុក ឱ្យមានសម្ទុះកាន់តែខ្លាំងក្លា ។

ច្បាស់ណាស់ថា នៅក្នុងបរិបទថ្មីនេះ, កម្ពុជាត្រូវសម្របជាប្រចាំ តាមនិន្នាការប្រែ-ប្រួលសកល ដែលទាមទារនូវការយកចិត្តទុកដាក់ខ្ពស់ ចំពោះការលើកកម្ពស់ភាពជាអ្នក-ដឹកនាំ និង សមត្ថភាពស្ថាប័នគ្រប់កម្រិត ដោយផ្សារភ្ជាប់នឹងការធានាបាន នូវគោល-

នយោបាយសមស្រប និង សមត្ថភាពអនុវត្តជាក់ស្តែង, លទ្ធផលការងារ និង ការទទួលខុសត្រូវ ដើម្បីឆ្លើយតបនឹងអាទិភាពសំខាន់ៗ នៅក្នុងដំណាក់កាលថ្មី រួមមានៈ ការពង្រឹងអភិបាលកិច្ច; ការទ្រទ្រង់កំណើន និង ការធ្វើទំនើបកម្មសេដ្ឋកិច្ច; ការបង្កើតការងារ, ទាំងគុណភាព និង បរិមាណ; ការលើកស្ទួយវិស័យឯកជន និង សហគ្រិនភាព; ការកសាងមូលធនមនុស្ស ដោយផ្តោតជាពិសេស លើគុណភាពវិស័យអប់រំ, សេវាសុខាភិបាល និង សីលធម៌សង្គម; ការលើកស្ទួយសេវាគាំពារសង្គម និង សុខុមាលភាពប្រជាជន, ជាពិសេស សម្រាប់គ្រួសារងាយរងហានិភ័យ និង ក្រុមជនងាយរងគ្រោះ; ការពង្រឹងគុណភាពនគរូបនីយកម្ម, ជាពិសេស ការកាត់បន្ថយគម្លាតរវាងទីក្រុង និង ជនបទ; ការពង្រឹងចីរភាពបរិស្ថាន និង ការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ; ព្រមទាំងការជំរុញធ្វើបរិវត្តកម្មឌីជីថល, ទាំងក្នុងសង្គម និង សេដ្ឋកិច្ច ។

នៅក្នុងក្របខណ្ឌនៃទស្សនវិស័យនេះ និង ផ្អែកតាម **កម្មវិធីនយោបាយ** របស់ខ្លួន, រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា, ក្រោមការដឹកនាំដ៏ស្វាហាប់ និងឈ្លាសវៃ ប្រកបដោយចក្ខុវិស័យវែងឆ្ងាយ របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** ដែលជាអគ្គមគ្គុទ្ទេសក៍វ័យក្មេងដ៏ឆ្នើម និង ពោរពេញដោយសមត្ថភាព, ចំណេះដឹង និងថាមពល, បានដាក់ចេញ នូវ **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** ដើម្បី **កំណើន, ការងារ, សមធម៌, ប្រសិទ្ធភាព, និង ចីរភាព** ដោយបានកំណត់យក **អាទិភាពគន្លឹះ ៥** គឺ៖ «**មនុស្ស, ផ្លូវ, ទឹក, ភ្លើង,** និង **បច្ចេកវិទ្យា,** ជាពិសេស គឺ **បច្ចេកវិទ្យាឌីជីថល**» សម្រាប់ឆ្លើយតបទៅនឹងបដិវត្តឧស្សាហកម្មទី ៤.០ និង បរិវត្តកម្មឌីជីថលនៃសេដ្ឋកិច្ច និង សង្គមកម្ពុជា ក៏ដូចជាឆ្លើយតបនឹងតម្រូវការ ក្នុងការលើកកម្ពស់ផលិតភាពសេដ្ឋកិច្ច ដែលជាគ្រឹះ និង ជាមធ្យោបាយដ៏សំខាន់ ក្នុងការសម្រេចបាននូវ **ចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០** សំដៅប្រែក្លាយកម្ពុជា ទៅជាប្រទេសមានចំណូលខ្ពស់ ។ **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** ក៏បានកំណត់ដាក់ចេញផងដែរ នូវ **គោលដៅយុទ្ធសាស្ត្រជាក់លាក់ ចំនួន ៥**, ដែល **គោលដៅយុទ្ធសាស្ត្រទី ៥** គឺ៖ ការធានាចីរភាពនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និង កសាងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ។

លើសពីនេះទៀត, កម្ពុជាក៏បានធ្វើការប្តេជ្ញាចិត្តខ្ពស់ ប្រកបដោយមហិច្ឆតា ក្នុងការចូលរួមទប់ស្កាត់បញ្ហានៃការប្រែប្រួលអាកាសធាតុ ដូចបានគូសរំលេចនៅក្នុងឯកសារ

«**ការរួមចំណែករបស់ជាតិ ស្ដីពីការប្រែប្រួលអាកាសធាតុ**» (Nationally Determined Contributions) និង «**យុទ្ធសាស្ត្ររយៈពេលវែង សម្រាប់អព្យាក្រឹតភាពកាបូន**» (Long-Term Strategy for Carbon Neutrality) ដើម្បីសម្រេចបាននូវអព្យាក្រឹតភាពកាបូន នៅឆ្នាំ ២០៥០ ។ ជាមួយគ្នានេះ, ក្នុងសេចក្ដីព្រាង «**ក្របខណ្ឌគោលនយោបាយហិរញ្ញប្បទានជាតិ**» ដែលត្រូវបានគាំទ្រ និង ចូលរួមសហការរៀបចំ ដោយ «**កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ**» (United Nations Development Programme), កម្ពុជា ក៏បាន និង កំពុងរៀបចំ ក្របខណ្ឌហិរញ្ញប្បទានការពារហានិភ័យ ពីគ្រោះមហន្តរាយ និង ការប្រែប្រួលអាកាសធាតុ ឱ្យកាន់តែទូលំទូលាយជាងមុន ផងដែរ ។

## ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី!

ក្នុងរយៈពេល ៤ ថ្ងៃ នៃ «**កម្មវិធីផ្លាស់ប្ដូរចំណេះដឹង ក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក**», ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី នឹងបានសិក្សាស្វែងយល់បន្ថែម ពីបទពិសោធន៍របស់ប្រទេស នៅក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក ក្នុងការអនុវត្តកម្មវិធីនានាដែលគាំទ្រដោយ **មូលនិធិវិនិយោគអាកាសធាតុ** មានជាអាទិ៍៖ **កម្មវិធីសាកល្បង សម្រាប់ភាពធន់នឹងអាកាសធាតុ** (Pilot Program for Climate Resilience) ឬ ហៅកាត់ថា «PPCR» និង **កម្មវិធីវិនិយោគព្រៃឈើ** (Forest Investment Program) ឬ ហៅកាត់ថា «FIP» ។ ទន្ទឹមនេះ, «**កម្មវិធីផ្លាស់ប្ដូរចំណេះដឹង ក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក**» ក៏នឹងដើរតួនាទីជាវេទិកាដ៏សំខាន់ សម្រាប់ថ្នាក់ដឹកនាំ, អ្នករៀបចំគោលនយោបាយ, និង មន្ត្រីជំនាញគ្រប់ជាន់ថ្នាក់នៃបណ្ដាប្រទេសក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក សម្រាប់ការបង្ហាញនូវនវានុវត្តភាព, ការចែករំលែកនូវលទ្ធផល និង ការពិភាក្សាអំពីបញ្ហាប្រឈម និង មេរៀននានាដែលខ្លួនបានជួបប្រទះ ក្នុងកិច្ចដំណើរការអនុវត្តកម្មវិធីអភិរក្ស និង រក្សានិរន្តរភាពព្រៃឈើ និង កម្មវិធីពង្រឹងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ។

ខ្ញុំក៏សូមយកឱកាសដ៏កម្រនេះ អំពាវនាវដល់សមាជិក-សមាជិកានៃក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ ព្រមទាំងភ្ញៀវកិត្តិយសមកពីបណ្ដាប្រទេស ទាំង ១៤ ក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក ដែលមានវត្តមាននៅទីនេះ, បន្តពង្រឹង និង ពង្រីកកិច្ចសហប្រតិបត្តិការជិតស្និទ្ធក្នុងចំណោមបណ្ដាប្រទេសជាសមាជិកទាំងអស់នៃមូលនិធិវិនិយោគអាកាសធាតុ ពីព្រោះប្រសិនបើមិនមានកិច្ចសហការស្អិតល្មួតនោះទេ, យើងនឹងជួបការលំបាកកាន់តែច្រើន ក្នុង

ការពង្រឹងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ, ការការពារបរិស្ថានធម្មជាតិ និង ការ-រក្សាសុខុមាលភាពរបស់ប្រជាជន ។

មុននឹងបញ្ចប់, ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះ **មូលនិធិវិនិយោគអាកាសធាតុ** និង **ធនាគារអភិវឌ្ឍន៍អាស៊ី** សម្រាប់ការប្ដេជ្ញាចិត្តមោះមុតឥតងាករេ ចំពោះបុព្វហេតុនៃការពង្រឹងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និង ការការពារបរិស្ថាន ។ ខ្ញុំក៏សូមកោតសរសើរ និង វាយតម្លៃខ្ពស់ ចំពោះឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី, សមាជិក-សមាជិកា, ជាតំណាងនៃបណ្ដាប្រទេស, តំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ, ដៃគូអភិវឌ្ឍន៍, វិស័យឯកជន និង អង្គការសង្គមស៊ីវិល, ដែលបានលះបង់នូវកម្លាំងកាយ-ចិត្ត និង ប្រាជ្ញា-ស្មារតី, ចូលរួមខិតខំកសាងបរិស្ថានដ៏ល្អមួយទៅអនាគតសម្រាប់យើង និង កូនចៅជំនាន់ក្រោយរបស់យើងទាំងអស់គ្នា ប្រកបដោយចីរភាព ។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា កម្មវិធីផ្លាស់ប្ដូរចំណេះដឹងនេះ នឹងប្រព្រឹត្តទៅដោយរលូន និង ទទួលបានផ្លែផ្កា តាមការរំពឹងទុក ។ ជាមួយគ្នានេះ, ខ្ញុំក៏សង្ឃឹមថា គណៈប្រតិភូអន្តរជាតិទាំងអស់ នឹងស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយផាសុកភាព ជាមួយនឹងអនុស្សា-វរីយ៍ល្អៗ និង វិលត្រឡប់ទៅកាន់ប្រទេសរៀងៗខ្លួនវិញ ដោយសុខសុវត្ថិភាព បន្ទាប់ពីកម្មវិធីរបស់យើងត្រូវបានបញ្ចប់ ដោយជោគជ័យ ។

នៅទីបញ្ចប់, ខ្ញុំសូមជូនពរឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី, និង ភ្ញៀវកិត្តិយសទាំងអស់, បានប្រកបដោយសុខភាពល្អបរិបូរណ៍, កម្លាំងមាំមួន និង សម្រេចបានជោគជ័យដ៏ត្រចះត្រចង់ក្នុងគ្រប់ភារកិច្ច ព្រមទាំងទទួលបាននូវវិបុលភាព និង សុភមង្គល ក្នុងក្រុមគ្រួសាររៀងៗខ្លួន ។

ខ្ញុំសូមប្រកាសបើក «**កម្មវិធីផ្លាស់ប្ដូរចំណេះដឹង ក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក** (Asia-Pacific Knowledge Exchange)» ចាប់ពីពេលនេះតទៅ ៕

***សូមអរគុណ !***